ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

នាមនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

**********

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៤៩៧
ចុះថ្ងៃទី ២១_០៨_២០០៩
សាលដីកា
លេខ : ១០៥ "ខ"
ចុះថ្ងៃទី ២២_១០_២០១០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣_១០_២០១០ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៤៩៧ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៩ ដែលមានៈ

- ជនជាប់ចោទឈ្មោះ [redacted] **គីមអួន** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ មុខរបរនេសាទ កើតនៅនៅភូមិ៣២ ឃុំត្បូងឃ្មុំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំនៅមុន[redacted] ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ២២-០២-២០០៩ ឃុំខ្លួនថ្ងៃទី ២៤-០២-២០០៩ នៅពន្ធនាគារខេត្តព្រះសីហនុ។

មានលោក[redacted]**ចន្ធា** មេធាវីការពារ។

**ជាប់ចោទពីបទៈ** រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅផ្ទះសំណាក់ ១៧១ ក្រុម១៥ ភូមិ៣ សង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **ហន** ភេទស្រី អាយុ ៣៥ឆ្នាំ ទីលំ[redacted] ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

- ជនរងគ្រោះឈ្មោះ[redacted]**គឹងអេង** ភេទស្រី អាយុ ១៣ឆ្នាំ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៩៣ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] **គឹមអួន** ជាជនជាប់ចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៨ "គ" ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## ឯដំណើររឿងមានដូចតទៅៈ

កាលពីថ្ងៃទី ២២-០២-២០០៩ វេលាម៉ោង ១ និង ០៨នាទី រំលងអាធ្រាត ស្ថិតនៅផ្ទះសំណាក់ ១៧១ បន្ទប់លេខ B៨ ក្រុមទី១៥ ភូមិ៣ សង្កាត់៤ ក្រុងព្រះសីហនុ មានករណីរំលោភសេពសន្ថវៈ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **គឹមអួន** បានធ្វើសកម្មភាពរំលោភលើកុមារី រងគ្រោះឈ្មោះ [redacted] **គឹមអេង** ដែលត្រូវជាកូនបង្កើតរបស់ខ្លួន ដែលមុនដំបូង ថ្ងៃទី ២១-០២-២០០៩ វេលាម៉ោង ២១ ជនជាប់ចោទបានយកឡានដឹកកូនដើរលេងហូបចំណី រួចដឹកត្រឡប់មកផ្ទះវិញ ក៏មានជម្លោះជាមួយប្រពន្ធ ពេលនោះជនជាប់ចោទ ក៏ដឹកកូនទាំងពីរចេញមកវិញ ដោយបានទិញស្រាស្បាយ ៥ដប រួចក៏បើកបង្ហួសទៅផ្ទះសំណាក់ ១៧១ ពេលនោះជនរងគ្រោះ និងប្អូនប្រុសម្នាក់ទៀតដេកលង់លក់ រីឯជនជាប់ចោទអង្គុយហូបស្រាតែម្នាក់ឯង។ លុះវេលាម៉ោង ១ និង ០៨នាទី ជនរងគ្រោះភ្ញាក់ក៏ឃើញឪពុកដេកក្បែរខ្លួន ពេលនោះជនជាប់ចោទ ក៏ចាប់ច្របាច់កជនរងគ្រោះមិនឱ្យស្រែក រួចចាប់សម្រាតសំលៀកបំពាក់ជនរងគ្រោះចេញអស់ បន្ទាប់មកជនជាប់ចោទដោះសំលៀកបំពាក់របស់ខ្លួនចេញ ហើយក៏យកប្រដាប់ភេទដាក់បញ្ចូលទៅក្នុងប្រដាប់ភេទជនរងគ្រោះ ប្រមាណ ២-៣នាទី ទើបឈប់ រួចក៏ឱ្យជនរងគ្រោះទៅមុជទឹក បន្ទាប់មកក៏ទៅដេករៀងៗខ្លួនទៅ។ លុះស្អែកឡើងទើបនាំកូនត្រឡប់មកផ្ទះ ពេលមកដល់ផ្ទះជនរងគ្រោះក៏លួចប្រាប់យាយរបស់ខ្លួន បណ្តាលឱ្យមានការភ្ញាក់ផ្អើលក្នុងគ្រួសារ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៨ "គ" ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលបានសម្រេចសេចក្តីដូចខាងក្រោមៈ**

១- ផ្តន្ទាទោសលើឈ្មោះ [redacted] **គឹមអួន** ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ របររកស៊ីនេសាទ កើតនៅឃុំត្បូងឃ្មុំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំ[redacted] ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់រយៈពេល ១៥ឆ្នាំ(ដប់ប្រាំឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ២៤-០២-២០០៩ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅផ្ទះសំណាក់ ១៧១ ក្រុម ១៥ ភូមិ ៣ សង្កាត់ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- វត្ថុតាងរួមមាន រថយន្តម៉ាកកាមរីសេរីឆ្នាំ១៩៩៥ ពណ៌បៃតងចាស់ចំនួន ០១គ្រឿង និងខោស្លឹបពណ៌ផ្កាឈូកចំនួន ០១ សម្រេចប្រគល់ឱ្យទៅម្ចាស់ដើមប្រើប្រាស់វិញ។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារជនជាប់ចោទ និងមេធាវីការពារជនរងគ្រោះ។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៥៣ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted] គឹមអួន ជាជនជាប់ចោទ ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៨ "គ" ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ[redacted] គឹមអួន បានឆ្លើយនៅសាលាដំបូងខេត្តព្រះសីហនុ។

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] ហាន បានឆ្លើយនៅសាលាដំបូងខេត្តព្រះសីហនុ។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិនិត្យសំណុំរឿង អង្គហេតុ ភស្តុតាង សាក្សី ចម្លើយជនជាប់ចោទ ជនរងគ្រោះ ឃើញថា ជនជាប់ចោទពិតជាបានរំលោភជនរងគ្រោះពិតប្រាកដមែន ហើយសាលាដំបូងសម្រេចត្រឹមត្រូវតាមច្បាប់ ដូច្នេះ សូមក្រុមប្រឹក្សាមេត្តាសម្រេចតម្កល់សាលក្រមទុកជាបានការដដែល។

## សេចក្ដីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានស្ដាប់របាយការណ៍ និងសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ខ្លួនសូមលើកករណីចម្លើយរបស់កូនក្ដីខ្លួនដែលបានឆ្លើយថា ខ្លួនពិតជារំលោភកូនស្រីខ្លួនប្រាកដមែន តែនៅពេលចូលសណ្ដាគារ គឺកូនក្ដីខ្លួនបានហូបស្រាយ៉ាងច្រើន ទើបធ្វើឱ្យមិនមានស្មារតីច្បាស់លាស់ថា កូន ឬប្រពន្ធនោះទេ។ សំណូមពរ សុំក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្ដីខ្លួនផង។

- ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្ដឹងឧទ្ធរណ៍លេខ ៥៣ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] គឹមអួន ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទបានឆ្លើយសារភាពថា កាលពីថ្ងៃទី ២២-០២-២០០៩ ខ្លួនពិតជាបានរំលោភសេពសន្ថវៈជនរងគ្រោះជាកូនស្រីខ្លួនពិតប្រាកដមែន ដោយខ្លួនផឹកស្រាស្រវឹងស្មានតែប្រពន្ធខ្លួន។ នៅថ្ងៃនោះមុនកើតហេតុខ្លួនបាន

ដឹកកូនយកទៅដេកក្នុងផ្ទះសំណាក់ លុះម៉ោងប្រហែលជាជាង ១ រំលងអាធ្រាត្រ ខ្លួនក៏បានធ្វើសកម្មភាពចាប់រំលោភកូនស្រីនៅពេលកំពុងដេកលក់ ពេលនោះកូនស្រែករើបម្រះ តែខ្លួនមិនលែងរំលោភរហូតបានសម្រេច។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅផ្ទះសំណាក់ ១៧១ ក្រុម ១៥ ភូមិ ៣ សង្កាត់ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០៩ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ២៨ "គ" ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៣ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] **គឹមអួន** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៨ "គ" ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១០ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ៗ**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted], [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ៣១ ខែ 12 ឆ្នាំ២០១០

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]